អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សូមគោរពជូន

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន

ប្រធានកាកបាទក្រហមកម្ពុជា

សម្តេចជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !

ក្នុងឱកាសខួប១៥២ឆ្នាំនៃទិវាកាកបាទក្រហម អឌ្ឍចន្ទក្រហមអន្តរជាតិ នាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ នេះ ខ្ញុំបាទ ភរិយា បុត្រា បុត្រី ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្រោមឱវាទនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមសម្តែងនូវការអបអរសាទរចំពោះសមិទ្ធផល និង គុណបំណាច់ដ៏ធំធេងរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលបានសម្រេចក្នុងការបម្រើបុព្វហេតុមនុស្សធម៌ នៅក្នុងក្របខ័ណ្ឌកាកបាទក្រហមកម្ពុជាជារួម និង ដោយឡែកនៅក្នុងសកម្មភាពសំខាន់ៗជាច្រើនឥតគណនាក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ។

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជាបានបំពេញតួនាទីនាំមុខដោយជោគជ័យរហូតត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ជា ឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ចំពោះការឆ្លើយតបមេរោគអេដស៍ និង ជំងឺអេដស៍ ។ ម្យ៉ាងទៀត ក្រោមការដឹកនាំដ៏មានប្រសិទ្ធភាពរបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត និង ការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៃព្រះរាជាណាចក្រកម្ពុជាយើងក៏ទទួលបាននូវពានរង្វាន់សហស្សវត្សរ៍ពីអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០១០ ។ ទាំងនេះជាមោទនភាពជាតិយើងទាំងមូល ។

សម្តេចបានបំពេញភារកិច្ចដោយមិនចេះនឿយហត់ ក្នុងការបន្តជួយការពារកុំឱ្យមានការរើសអើង និង មាក់ងាយអ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺអេដស៍ ព្រមទាំងបានផ្តល់នូវការឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាង ទាំងស្មារតី និង សម្ភារៈដល់អ្នកផ្ទុកមេរោគអេដស៍ ។ ប្រសាសន៍ដ៏ថ្លៃថ្នូរបស់សម្តេចក្នុងការប្រយុទ្ធនឹងជំងឺអេដស៍នៅ គ្រប់វេទិកា និងជាញឹកញាប់ បាននាំឱ្យមានការយកចិត្តទុកដាក់ពីមជ្ឈដ្ឋានជាតិ និង អន្តរជាតិ ដែលជាហេតុនាំឱ្យមានការគាំទ្រដល់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ដល់កម្ពុជាឥតឈប់ឈរ ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង បុត្រា បុត្រី និង ចៅប្រុសចៅស្រីជាទីស្រឡាញ់ ក្នុងខួបលើកទី១៥២ឆ្នាំ ទិវាកាកបាទក្រហម អឌ្ឍចន្ទក្រហមអន្តរជាតិ សូមជួបប្រទះតែសេចក្តីសុខ សុភមង្គល និង ប្រកបដោយពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសម្តេច មានសុខភាពបរិបូណ៌ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំកសាង និង អភិវឌ្ឍន៍មាតុភូមិឱ្យកាន់តែរីកចម្រើនរុងរឿងថែមទៀតតរៀងទៅ ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥

ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង - មូលី

អាសយដ្ឋាន: អគារលេខ ១៦ ផ្លូវលេខ ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់ II ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារ (៨៥៥-២៣) ៨៨៥ ១២៩